# សេចក្តីប្រកាស
# ការផ្តល់កញ្ចប់ថវិកាសម្រាប់ការសរសេរនិក្ខេបបទ / សិក្សាស្រាវជ្រាវ

## សេចក្តីផ្តើម៖

យេនឌ័រនិង អភិវឌ្ឍន៍ដើម្បីកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងមិនរកប្រាក់ចំណេញ ។ បេសកកម្មរបស់យើងគឺដើម្បីលើកកម្ពស់សមភាពយេនឌ័រ ដែលជាសិទ្ធិមនុស្ស ជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចនិងនយោបាយរបស់ប្រទេសកម្ពុជា។ អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជាធ្វើការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងជាសមាជិកនៃអង្គការសង្គមស៊ីវិល ក្នុងការតស៊ូមតិសម្រាប់បញ្ជ្រាបយេនឌ័រក្នុង គម្រោង និងកម្មវិធី ច្បាប់ជាតិ និងការបង្កើតគោលនយោបាយក្នុងប្រទេសកម្ពុជា។

អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា មានសេចក្តីរីករាយក្នុងការប្រកាសពីជំនួយថវិកាខ្នាតតូចរបស់ខ្លួនសម្រាប់ការសរសេរ និក្ខេបបទ ឬ ការសិក្សាស្រាវជ្រាវ ក្រោមមូលនិធិនៃ AECID បានតាមរយៈ PyD សម្រាប់ឆ្នាំ 2014 ។ ជំនួយថវិកានេះគឺការរួមចំណែកជួយដល់សិស្សថ្នាក់បរិញ្ញាបត្រ ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវរបស់ពួកគេ និង ជំនាញវិភាគលើបញ្ហាយេនឌ័រនៅក្នុងបរិបទកម្ពុជា។ បេក្ខជនដែល ទទួលបានជោគជ័យត្រូវបានលើកទឹកចិត្តក្នុងការប្រើជំនួយនេះដើម្បីប្រើប្រាស់លើការចំណាយ ដូចជាការចុះស្រាវជ្រាវ ទិញសៀវភៅ និងឯកសារ និងការបោះពុម្ពនិក្ខេបបទរបស់ពួកគេជាដើម។

## លក្ខខណ្ឌចូលរួម៖

ជំនួយថវិកាខ្នាតតូចនេះគឺសំរាប់សិស្សបរិញ្ញាប័ត្រ (ជាបុគ្គល ឬជាក្រុម) ពីសាកលវិទ្យាល័យនៅប្រទេសកម្ពុជា និង ដែលស្ថិតនៅក្នុងដំណើការនៃការសរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្ររបស់ខ្លួនឬដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើការសិក្សាស្រាវជ្រាវលើបញ្ហាយេនឌ័រនៅក្នុងមុខវិជ្ជានៃការសិក្សារបស់ពួកគេ។ និស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់នៅក្នុងវិស័យ អាជីវកម្ម សេដ្ឋកិច្ច កសិកម្ម ការអភិវឌ្ឍន៍ជនបទ ការអប់រំ សិល្បៈ វិទ្យាសាស្រ្ត សង្គម ច្បាប់ បច្ចេកវិទ្យានិងវិស័យផ្សេងទៀតត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យ។

និស្សិតស្រីត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យស្នើសុំកញ្ចប់ថវិកានេះ។

## ដំណើរការនៃការដាក់ពាក្យ៖

បេក្ខជនចាំបាច់ត្រូវដាក់ពាក្យស្នើសុំកញ្ចប់ថវិកា[1]។ នៅលើពាក្យស្នើសុំ បេក្ខជនត្រូវពណ៌នាលម្អិតពីគោលបំណងស្រាវជ្រាវរបស់ពួកគេ វិធីសាស្រ្តក្នុងការស្រាវជ្រាវ លទ្ធផលរំពឹងទុក និងផែនការការងាររបស់ពួកគេ។ សំណើរសុំកញ្ចប់ថវិកា និងសុំការស្រាវជ្រាវនេះត្រូវតែស្វែងរកបញ្ហាយេនឌ័រដែល ទាក់ទង ទៅនឹងមុខវិជ្ជាសិក្សាដូចជា ការចូលរួមរបស់ស្រ្តីក្នុងវិស័យកសិកម្ម បៀតបៀនផ្លូវភេទរបស់បុគ្គលិកភេទស្រីនៅក្នុងអាជីវកម្ម ឬបញ្ហាប្រឈមរបស់សិស្ស ស្រីនៅក្នុងវិស័យអប់រំឧត្តមសិក្សា។ល។

[1] ចូលទៅក្នុងគេហទំព័រខាងក្រោមដើម្បីទាញយកពាក្យស្នើសុំកញ្ចប់ថវិកា និងផ្ញើរពាក្យស្នើសុំនេះទៅសារអេឡិចត្រូនិចដែលបញ្ជាក់នៅខាងក្រោម។

លើសពីនេះទៀតបេក្ខជនត្រូវសរសេរផែនការប៉ាន់ប្រមាណការចំណាយលម្អិតក្នុងការស្រាវជ្រាវ និងសរសេរពីផែនការដាក់លាក់ នៃការសិក្សាស្រាវជ្រាវនេះ។

សំណើរសុំការស្រាវជ្រាវនឹងត្រូវបានជ្រើសរើសដោយគណៈកម្មាធិដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចជា៖

- បង្ហាញពីការរកឃើញថ្មីស្តីពីបញ្ហាយេនឌ័រដែលទាក់ទងទៅនឹងកម្មវិធីនៃការសិក្សាណាមួយ
- ការរកឃើញស្តីពីបញ្ហាយេនឌ័រនេះមានជះឥទ្ធិពល ទៅលើកម្មវិធីនៃការសិក្សាណាមួយ
- វិធីសាស្ត្រនៃការស្រាវជ្រាវត្រូវបញ្ជ្រាបទស្សនៈយេនឌ័រ
- សំណើរធ្វើការស្រាវជ្រាវត្រូវមានការយល់ព្រមពីសាលា ( សម្រាប់និក្ខេបបទ )

និក្ខេបបទ/ការស្រាវជ្រាវនេះ អាចជាភាសាអង់គ្លេស ឬភាសាខ្មែរ។

## កញ្ចប់ថវិកា៖

បេក្ខជន ឬក្រុម ដែលទទួលជោគជ័យនឹងទទួលបាន **$ 200** ក្នុងការចំណាយ ដូចជាការចុះស្រាវជ្រាវ ទិញសៀវភៅ និងឯកសារ ឬការបោះពុម្ពនិក្ខេបបទរបស់ខ្លួន ឬសំភារៈពាក់ព័ន្ធ / ចំណាយផ្សេងទៀត។ **ក្នុងឆ្នាំ 2014 កញ្ចប់ថវិកាមានទាំងអស់ចំនួន 4 សំរាប់និស្សិត។**

## លិខិតអនុញ្ញាតពីសាលា៖

បេក្ខជន ដែលសរសេរនិក្ខេបបទ ត្រូវយកលិខិតអនុញ្ញាតឲ្យសរសេរនិក្ខេបបទពីសាលា មកភ្ជាប់ជាមួយពាក្យស្នើសុំកញ្ចប់ថវិកា ឬក៏ឲ្យអ្នកផ្តល់ប្រឹក្សាក្នុងការសរសេរចុះហត្ថលេខាលើពាក្យស្នើសុំកញ្ចប់ថវិកា។

## ថ្ងៃផុតកំណត់៖

ថ្ងៃផុតកំណត់នៃការដាក់ពាក្យស្នើសុំថវិកា **30 ខែ *សីហា* 2014**។

## ទំនាក់ទំនង:

សូមផ្ញើពាក្យស្នើសុំថវិកាទៅ៖
កញ្ញា ភឹង ផារីន , ជំនួយការនាយិកាប្រត្តិបត្ត អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា
ទូរស័ព្ទ៖ 011 607 072
សារអេឡិចត្រូនិច៖ eda@gadc.org.kh

អាស័យដ្ឋាន
អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា
ផ្ទះលេខ 89 ផ្លូវ 288 សង្កាត់អូឡាំពិច ខ័ណ្ឌចំការមន ភ្នំពេញ
ទូរសព្ទ៖ 023 215 137
ទូរសារ៖ 023 996 934
**គេហទំព័រ៖ www.gadc.org.kh**